**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសអបអរសាទរការប្រារព្ធទិវា "ឆ្នាំទេសចរណ៍ និងវប្បធម៌ ចិន-កម្ពុជាដំបូង"

**ថ្ងៃពុធ ១០រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២**

**ត្រូវនឹងថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៩**

ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកដោយបានចូលរួមអបអរសាទរការប្រារព្ធទិវា "**ឆ្នាំទេសចរណ៍ និងវប្បធម៌ ចិន-កម្ពុជាដំបូង**"។ ខ្ញុំក៏សូមស្វាគមន៍យ៉ាងកក់ក្តៅផងដែរចំពោះដំណើរទស្សនកិច្ចរបស់**ឯកឧត្តម ឡួ ស៊ូកាង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងទេសចរណ៍នៃសាធារណរដ្ឋប្រជាមានិតចិន** មកកាន់ដែនដីសុវណ្ណភូមិនៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមអបអរសាទរចំពោះសមិទ្ធិផលដ៏អស្ចារ្យរបស់មិត្តចិនឆ្នាំ២០១៨កន្លងមក ក្រោមកិច្ចប្រឹងប្រែងប្រកបដោយការគិតគូរវែងឆ្ងាយ និងមិនចេះនឿយហត់របស់**ឯកឧត្តម ស៊ី ជីងពីន** ដែលបានធ្វើឲ្យមានទំនុកចិត្តពេញទំហឹងពីប្រជាជនចិន ក្នុងដំណើរការជំរុញប្រទេសចិនឲ្យបោះជំហានទៅមុខរយៈពេលដ៏យូរអង្វែងទៅអនាគត ជាពិសេសកសាងប្រទេសចិនឲ្យក្លាយជាប្រទេសសង្គមនិយមទំនើបប្រកបដោយវិបុលភាព រឹងមាំ មានវប្បធម៌ឈានមុខ មានភាពសុខដុម្ម និងល្អរុងរឿង។

ក្នុងនាមជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ កម្ពុជា និងចិនមានទំនាក់ទំនងមិត្តភាពជាប្រពៃណីដ៏ល្អប្រសើរ និងមានកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ ហើយកំពុងរីកចម្រើនលើវិស័យនានាជាច្រើន។ ការប្រាស្រ័យទាក់ទងគ្នាយ៉ាងស្និតរមួត និងការផ្លាស់ប្តូរទស្សនកិច្ចដ៏មមាញឹកគ្រប់ជាន់ថ្នាក់ក្នុងបណ្តាឆ្នាំថ្មីៗនេះរួមមាន កិច្ចប្រជុំមេគង្គ-ឡានឆាង លើកទី២ នៅរាជធានីភ្នំពេញ វេទិកាទេសចរណ៍កំពូលលើកដំបូងរវាងកម្ពុជា-ចិន និងការរៀបចំខួបអនុស្សាវរីយ៍លើកទី៦០នៃការភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរកាលពីឆ្នាំ២០១៨ ជាពិសេសដំណើរទស្សនកិច្ចផ្លូវការរបស់ខ្ញុំទៅកាន់រដ្ឋធានីប៉េកាំងកាលពីពេលថ្មីៗនេះ បានពង្រឹងឲ្យកាន់តែរឹងមាំខ្លាំងក្លាថែមទៀតនូវស្មារតីសាមគ្គីភាព មិត្តភាព និងភាតរភាព រវាងប្រជាជាតិទាំងពីរ។

ពិតណាស់ថា ទេសចរណ៍ និងវប្បធម៌មានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតប្រៀបបានសរសៃអំបោះដែលវេញចូលគ្នា ដែលចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងនូវភាពទាក់ទាញ និងភាពប្រកួតប្រជែងសម្រាប់តំបន់ទេសចរណ៍ ក៏ដូចជាសម្រាប់ប្រទេសជាតិ។ ជាក់ស្តែង វិស័យវប្បធម៌បានដើរតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់អភិវឌ្ឍជាផលិតផលទេសចរណ៍ ដែលអាចបង្កើតជាភាពទាក់ទាញសម្រាប់តំបន់មួយឬប្រទេសមួយនៅក្នុងទីផ្សារទេសចរណ៍ដែលកំពុងតែមានការប្រកួតប្រជែងកាន់តែខ្លាំង។ ជាមួយគ្នានេះដែរ

វិស័យទេសចរណ៍បានបង្កើតនូវប្រភពចំណូល និងធនធាន ដែលអាចគាំទ្រ និងពង្រឹងការអភិរក្ស និងអភិវឌ្ឍវប្បធម៌ក្នុងយុគសម័យនៃភាពច្នៃប្រឌិត និងសាកលភាវូបនីយកម្ម។

ទេសចរណ៍ និងវប្បធម៌ ក៏ត្រូវបានផ្សារភ្ជាប់តាមរយៈសក្ដានុពលនៃកំណើននៃវិស័យទាំងពីរផងដែរ ដោយក្នុងនោះ ទេសចរណ៍វប្បធម៌គឺជាទីផ្សារទេសចរណ៍ពិភពលោកដែលមានទំហំធំជាងគេ និងមានការកើនឡើងខ្លាំងជាងគេ ហើយវប្បធម៌ និងសិល្បៈច្នៃប្រឌិត ត្រូវបានកំពុងប្រើប្រាស់កាន់តែខ្លាំងឡើងដើម្បីផ្សព្វផ្សាយពីគោលដៅទេសចរណ៍នីមួយៗ។ ការប្រើប្រាស់ និងការច្នៃប្រឌិតវប្បធម៌ដើម្បីបង្កើនភាពទាក់ទាញនៃទីផ្សារទេសចរណ៍ បានកំពុងជំរុញឲ្យមានភាពសំបូរបែបនៃអត្តសញ្ញាណក្នុងតំបន់ និងលើកស្ទួយរូបភាពនៃគោលដៅទេសចរណ៍នោះ។

ក្នុងន័យនេះ ការរៀបចំទិវា **"ឆ្នាំទេសចរណ៍ និងវប្បធម៌ ចិន-កម្ពុជាដំបូង"** ព្រមជាមួយដំណើរទស្សនកិច្ចរបស់ឯកឧត្តម **ឡូ ស៊ីកាង** មកកាន់កម្ពុជានាពេលនេះ នឹងរួមចំណែកធ្វើឲ្យកាន់តែស៊ីជម្រៅថែមទៀតនូវចំណងទាក់ទងជាបងប្អូន និងពង្រីកវិសាលភាពកិច្ចសហប្រតិបត្តិការឲ្យកាន់តែស៊ីជម្រៅក្នុងក្របខណ្ឌ "ខ្សែក្រវាត់ និងផ្លូវ" ដើម្បីបំរើផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជន និងទេសចរណ៍រវាងប្រជាជាតិទាំងពីរ ក្នុងនាមជាអារ្យប្រទេសដែលមានវប្បធម៌ដ៏ចំណាស់ យូរលង់ និងឧត្តុង្គឧត្តម និងជាអ្នកជិតខាងល្អចេះជួយគ្នាទៅវិញទៅមក។

ទន្ទឹមនឹងនេះ ខ្ញុំមានសុទ្ធិនិយមថា ការរៀបចំទិវា **"ឆ្នាំទេសចរណ៍ និងវប្បធម៌ ចិន-កម្ពុជាដំបូង"** នេះនឹងក្លាយជាកាលានុវត្តភាពដ៏ប្រសើរថ្មីបន្ថែមទៀតក្នុងស្រូបទាញនូវកំណើនភ្ញៀវទេសចរ និងវិនិយោគិនចិនមកទស្សនា និងបណ្ដាក់ទុនធុរកិច្ចនៅកម្ពុជាកាន់តែច្រើនថែមទៀត ខណៈដែលភ្ញៀវទេសចរចិនបានក្លាយជាប្រភពទីផ្សារទេសចរណ៍ឈានមុខគេប្រកបដោយថាមភាពសម្រាប់ពិភពលោក ក៏ដូចជាសម្រាប់កម្ពុជាទាំងនៅពេលបច្ចុប្បន្ន និងទៅអនាគត ជាពិសេសជម្រុញការអភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌នៅកម្ពុជា ទាំងបរិមាណ និងគុណភាព និងសូមគាំទ្រឲ្យមានការរៀបចំទិវា **"ឆ្នាំទេសចរណ៍ និងវប្បធម៌ ចិន-កម្ពុជា"** លើកទី២ នាឆ្នាំ២០២០ខាងមុខបន្តទៀត។

ជាមួយគ្នានេះ ខ្ញុំជឿជាក់យ៉ាងមុតមាំថា តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្តម **ឡូ ស៊ីកាង** នាពេលនេះ នឹងពង្រឹងបន្ថែមនូវមូលដ្ឋានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការផ្នែកទេសចរណ៍ និងវប្បធម៌កាន់តែរឹងមាំ និងជិតស្និទ្ធ ពិសេសគឺការស្វែងយល់រវាងគ្នាទៅវិញទៅមកឲ្យកាន់តែស៊ីជម្រៅលើភាពសម្បូរបែបនៃសម្បត្តិវប្បធម៌ និងទេសចរណ៍រវាងប្រទេសទាំងពីរ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យការប្រារព្ធទិវា **"ឆ្នាំទេសចរណ៍ និងវប្បធម៌ ចិន-កម្ពុជាដំបូង"** នេះ ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យដ៏ត្រចះត្រចង់ និងសូមជូនពរបងប្អូនជនរួមជាតិទាំងអស់ ជួបតែពុទ្ធពរទាំង៤ ប្រការគឺ *អាយុ វណ្ណៈ សុខៈ ពលៈ* កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១០ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩

**ហ៊ុន សែន**